**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០០២ ក្រ.បប

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

# ក្រមប្រតិបត្តិ

## ស្តីពី

## វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ក្នុងដំណាក់កាលកូវីដ-១៩ (COVID-19)

យោងតាមអង្គការសុខភាពពិភពលោក (WHO) បានឱ្យដឹងថា ក្នុងកំឡុងខែឧសភា ឆ្នាំ២០២០មានបណ្តាប្រទេសជាច្រើននៅលើពិភពលោកបានបង្ហាញថា ការឆ្លងនៃជំងឺកូវីដ-១៩ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានថយចុះ និងមានប្រទេសមួយចំនួនបានបិទបញ្ចប់ករណីឆ្លង (ឧទាហរណ៍៖ ប្រទេសកម្ពុជារាជរដ្ឋាភិបាលកម្ពុជាបានប្រកាសជោគជ័យនៃការទប់ស្កាត់ការីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០)។ ក្រមប្រតិបត្តិស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកនេះ ត្រូវបានរៀបចំដោយផ្អែកលើភស្តុតាងដែលអាចរកបានអំពីការឆ្លងនៃជម្ងឺកូវីដ-១៩ (ការឆ្លងពីមនុស្សជាចម្បងតាមរយៈដំណក់ទឹកតូចៗដែលចេញពីប្រព័ន្ធផ្លូវដង្ហើម ឬប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកដែលបានឆ្លងវីរុស) ហើយត្រូវបានរៀបចំឡើងដើម្បីធានាថា អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកនៅតែអាចការពារសុខភាពបុគ្គលិក និងភ្ញៀវទេសចររបស់ខ្លួនក្នុងដំណាក់កាលនៃការត្រៀមខ្លួនងើបឡើងវិញ (Early Recovery ឬហៅថាដំណាក់កាល (New Normal Life) នៃអាជីវកម្មរបស់ខ្លួន។

អ្នកផ្តល់សេវាដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹកត្រូវអនុវត្តតាមវិធាន ដូចខាងក្រោម៖

**១. សុវត្ថិភាព-អនាម័យនៅទីតាំងចំណត**

- ត្រូវសម្អាតកន្លែងអង្គុយរង់ចាំ និងបញ្ជរលក់សំបុត្រឱ្យបានញឹកញាប់ និងជាប្រចាំ
- ត្រូវមានទឹកអាល់កុល ឬជែលលាងដៃ ឬទឹកសម្លាប់មេរោគតាមបញ្ជរលក់សំបុត្រនីមួយៗ
- ត្រូវបិទសញ្ញាសំគាល់កន្លែងអង្គុយឱ្យបានត្រឹមត្រូវដោយអនុវត្តគោលការណ៍រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១.៥ម៉ែត្រ
- ត្រូវបិទសញ្ញាសំគាល់ទីតាំងឈរតម្រង់ជួរឱ្យបានត្រឹមត្រូវដោយអនុវត្តគោលការណ៍រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច ១.៥ម៉ែត្រ
- ត្រូវបិទគោលការណ៍ណែនាំអំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩របស់ក្រសួងសុខាភិបាលជាទម្រង់ Poster ឬ I-stand តាមទីតាំងចំណត និងទីតាំងងាយមើលឃើញ
- ត្រូវសម្អាតបន្ទប់ទឹកឱ្យបានញឹកញាប់ និងជាប្រចាំ ដោយត្រូវមានសាប៊ូលាងដៃ ឬទឹកសម្លាប់មេរោគជានិច្ច
- ត្រូវមានផែនការបាញ់សម្លាប់មេរោគនៅទីតាំងចំណតកាណូត។

**២. សុវត្ថិភាព-អនាម័យក្នុងកាណូតទេសចរណ៍**

- ត្រូវសម្អាតជាមួយសាប៊ូ ឬទឹកអាល់កុល ឬទឹកសម្លាប់មេរោគនូវទីតាំងក្នុងកាណូតដែលមានការប៉ះពាល់ញឹកញាប់ ដូចជា បង្កាន់ ដៃ ទ្រនាប់ពូក កៅអី ភ្នាក់ដៃកៅអី កញ្ចក់ និងបន្ទប់ទឹក (ប្រសិនបើមាន) ឱ្យបានញឹកញាប់
- ត្រូវបានអនុញ្ញាតឱ្យផ្ទុកទេសចរ និងអ្នកដំណើរដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១.៥ម៉ែត្រ ឬក្នុងកម្រិតអតិបរមា៥០%នៃចំនួនកៅអីសរុប ឬត្រូវឱ្យទេសចរ និងអ្នកដំណើរពាក់ម៉ាស់ ឬដាក់របាំងបែងចែកទីតាំងអង្គុយ
- ត្រូវបិទគោលការណ៍ណែនាំអំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាលជាទម្រង់ Poster យ៉ាងតិចពីរសន្លឹកក្នុងកាណូត
- ត្រូវមានទឹកអាល់កុល ឬជែលលាងដៃ ឬទឹកសម្លាប់មេរោគក្នុងកាណូតជាប្រចាំ។

**៣. សុវត្ថិភាពទេសចរ និងអ្នកដំណើរ**

- ត្រូវវាស់កម្ដៅគ្រប់ទេសចរ និងអ្នកដំណើរ មុននឹងឡើងកាណូត ដោយភ្ជាប់ជាមួយវិធានការបាញ់ទឹកអាល់កុល ឬជែលលាងដៃ ឬទឹកសម្លាប់មេរោគដល់គ្រប់ទេសចរ និងអ្នកដំណើរ
- ត្រូវបាញ់សម្អាតឥវ៉ាន់របស់អ្នកដំណើរ (ករណីឥវ៉ាន់ត្រូវបានផ្ទុកក្នុងទីតាំងអង្គុយ ឬក្បែរទីតាំងអង្គុយរបស់អ្នកទេសចរ ឬអ្នកដំណើរ)
- ត្រូវឱ្យទេសចរ និងអ្នកដំណើរពាក់ម៉ាស់ ឬចែកម៉ាស់ដល់ទេសចរ និងអ្នកដំណើរ។

**៤. សុវត្ថិភាពសម្រាប់បុគ្គលិកផ្តល់សេវាកម្ម**

- ត្រូវផ្សព្វផ្សាយគោលការណ៍ណែនាំអំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាលដល់បុគ្គលិកនិងអ្នកបើកបរ។ ចំពោះព័ត៌មានបន្ថែម សូមស្វែងរកតាមរយៈហ្វេសប៊ុកក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ឬគេហទំព័រ www.cdcmoh.gov.kh ឬលេខទូរស័ព្ទទាន់ហេតុការណ៍ (Hotline) ១១៥
- អ្នកបើកបរ និងបុគ្គលិកត្រូវពាក់ម៉ាស់ និងឧស្សាហ៍លាងដៃជាមួយទឹកអាល់កុល ឬសាប៊ូ ឬជែលលាងដៃ ឬទឹកសម្លាប់មេរោគឱ្យបានញឹកញាប់ ក្នុងអំឡុងពេលបម្រើសេវាកម្ម
- ត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រង ប្រសិនបើអង្កេតឃើញទេសចរ និងអ្នកដំណើរមានរោគសញ្ញាក្អក កណ្តាស់ គ្រុនក្តៅ រលាកបំពង់ក ហៀរសំបោរ ឬពិបាកដកដង្ហើម និងតម្រូវឱ្យទេសចរ និងអ្នកដំណើរពាក់ម៉ាស់ជាដាច់ខាត។

រដ្ឋមន្ត្រី

ថោង ខុន